# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការប្រឹក្សាការងារ**

## សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

ឆ្នាំ២០១៤ ខែកញ្ញា ថ្ងៃទី២៦ វេលាម៉ោង ១៥:០០ នាទីរសៀល គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំការងារ លើកទី១០ អាណត្តិទី៨ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៥ និងពិនិត្យលើអនុសាសន៍ទាំង ៤ របស់សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពី "លក្ខណៈវិនិច្ឆ័យផ្នែកសង្គម និងសេដ្ឋកិច្ចសម្រាប់ដំណើរការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា" កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ដោយមានសមាជិកចូលរួមចំនួន ២៦ លើចំនួនសរុប ២៨ រូប។ ក្រោយពីមានការពិគ្រោះយោបល់គ្នាយ៉ាងផុសផុល និងគ្រប់ជ្រុងជ្រោយ គណៈកម្មការប្រឹក្សាការងារបានសម្រេចដូចខាងក្រោម៖

១- កំណត់កាលបរិច្ឆេទពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៥ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ វេលាម៉ោង ៩:០០ នាទីព្រឹក ។

២- បានស្តាប់របាយការណ៍ស្តីពីលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ក្រោមជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិខាងការងារ។

៣-ភាគីពាក់ព័ន្ធទាំងអស់ឯកភាព នឹងបន្តកិច្ចខិតខំប្រឹងប្រែងពិភាក្សាគ្នាក្នុងស្មារតីសាមគ្គី រួបរួមការពារផលប្រយោជន៍រួមដោយន័យស្ថាបនា ។

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤*

| ប្រធានគណៈកម្មការប្រឹក្សាការងារ | អនុប្រធានគណៈកម្មការប្រឹក្សាការងារភាគីតំណាងនិយោជក | អនុប្រធានគណៈកម្មការប្រឹក្សាការងារភាគីតំណាងកម្មករនិយោជិត |
| --- | --- | --- |
| បណ្ឌិត **អ៊ិត សំហេង** | ឧកញ៉ាបណ្ឌិត **ណាង សុធី** | **ជួន មុំធុល** |